# សេចក្ដីណែនាំសម្រាប់មណ្ឌលសុខភាព

## ជំហានទី ១: ដំណាក់កាលដំបូង ដែលអ្នកជំងឺទៅមណ្ឌលសុខភាពដើម្បីពិនិត្យសុខភាពរកជំងឺរបេង



អ្នកជំងឺទៅមណ្ឌលសុខភាព

ជួបអ្នកពិគ្រោះជំងឺក្រៅ

- ដាក់តាំងផ្ទាំងរូបភាព នៅកន្លែងតុទទួលភ្ញៀវ- កន្លែងពិនិត្យជំងឺក្រៅ ( **OPD desk** )។
- ដាក់បណ្ណបញ្ជូន ( ពណ៌លឿង ) នៅខាងក្នុងផ្ទាំងរូបភាព

## ករណីទី ១: ប្រសិនបើអ្នកជំងឺមកមណ្ឌលសុខភាព ដោយគ្មានបណ្ណបញ្ជូន



រោគវិនិច្ឆ័យអ្នកជំងឺ → ពេទ្យឲ្យបណ្ណបណ្ជូន → ជួបជាមួយពេទ្យទទួលបន្ទុកខាងរបេង → ពិនិត្យកំហាក/តេស្ត → បោះត្រាលើបណ្ណបញ្ជូន

- បុគ្គលិកពីនិត្យជំងឺក្រៅ សាកសួរ និងវិភាគរោកសញ្ញាអ្នកជំងឺ។
    - ប្រសិនបើអ្នកជំងឺមានរោគសញ្ញាជំងឺរបេង ត្រូវផ្ដល់បណ្ណបញ្ជូនទៅគាត់ ហើយត្រូវប្រាប់អំពីកម្មវិធីលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុថា៖
        - អ្នកនឹងទទួលបាន ៤០០០រៀល ប្រសិនបើអ្នកជាប់លក្ខខណ្ឌ ក្នុងការពិនិត្យស្រាវជ្រាវរករបេង ( ពិនិត្យកំហាក ឬថតសួត ) បន្ទាប់មកអ្នក នឹងទទួលបាន ២០០០០រៀល បន្ថែមទៀតប្រសិនបើអ្នកលទ្ធផលមរបស់អ្នកមានជំងឺរបេង។
        - បន្ទាប់មកបុគ្គលិកពិនិត្យជំងឺក្រៅ ប្រាប់អ្នកជំងឺឱ្យទៅជួបជាមួយបុគ្គលិកទទួលបន្ទុកជំងឺរបេង ( TB Supporter ) ដើម្បីធ្វើការ ពិនិត្យស្រាវជ្រាវរកជំងឺរបេង។
        - អ្នកជំងឺទៅជួប និងបង្ហាញនូវបណ្ណបញ្ជូនទៅកាន់អ្នកគាំទ្រផ្នែកជំងឺរបេង។
    - បន្ទាប់មក TB supporter  បោះត្រានៅលើបណ្ណបញ្ជូន បញ្ជាក់ថា "បានស្រាវជ្រាវរករបេង" បន្ទាប់មកត្រូវប្រាប់អ្នកជំងឺថា ពួកគាត់នឹងត្រូវទទួលបាន ៤០០០រៀល ពីភ្នាក់ងារអប់រំ នៃគម្រោងលើកកម្ពស់ឥរិយាបថប្រកបដោយសុខុមាលភាព។ ភ្នាក់ងារអប់រំ នឹងទូរស័ព្ទទៅជួប និងទូទាត់ដោយផ្ទាល់ជាមួយពួកគាត់ម្នាក់ម្ដងៗ។ ប្រសិនបើលទ្ធផលនៃការស្រាវជ្រាវ បញ្ជាកថាអ្នកមានជំងឺរបេង អ្នកនឹងទទួលបាន ២០០០០រៀល បន្ថែមទៀត ដើម្បីឧបត្ថម្ភដល់មធ្យោបាយ ធ្វើដំណើររបស់អ្នក។ រំលឹកអ្នកជំងឺឱ្យរក្សាទុកបណ្ណបញ្ជូនដើម្បីទទួលបានការទូទាត់។

មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន

USAID ជំនួយពីពលរដ្ឋអាមេរិក

psi Cambodia

## ករណីទី ២: អ្នកជំងឺមកកាន់មណ្ឌលសុខភាព ដោយមានបណ្ណបញ្ជូន៖




- អ្នកពិនិត្យជំងឺក្រៅ ធ្វើរោគវិនិច្ឆ័យ អ្នកជំងឺ ហើយប្រសិនបើ ត្រូវតាមលក្ខណៈវិនិច្ឆ័យនៃជំងឺរបេងនោះ ប្រាប់ពួកគាត់ឱ្យ បង្ហាញបណ្ណ បន្ទាប់មកប្រាប់ពួកគាត់ ឱ្យទៅជួប TB supporter
- TB supporter អនុវត្តទៅតាមជំហានដូចគ្នា ដូចបានបង្ហាញនៅក្នុង ករណីទី ១។




- អ្នកជំងឺមកដល់មណ្ឌលសុខភាព ដើម្បីទទួលយកលទ្ធផលជំងឺរបេង (វិជ្ជមាន) និងដើម្បីទទួលការប្រឹក្សាពីគ្រូពេទ្យ។
  - គ្រូពេទ្យ (TB supporter ) ប្រាប់អំពីលទ្ធផលវិជ្ជមាន និងកម្មវិធីលើកទឹកចិត្តអ្នកជំងឺរបេង។
    - អ្នកទទួលលទ្ធផលវិជ្ជមាននៃជំងឺរបេង ប៉ុន្តែកុំបារម្ភអី ជំងឺរបេងអាចព្យាបាលជាសះស្បើយ ហើយយើងគាំទ្រអ្នកមិនត្រឹមតែសម្ភារៈរូបវន្តប៉ុណ្ណោះទេ (ថ្នាំ) ថែមទាំងគាំទ្រផ្នែកផ្លូវចិត្តទៀតផង (ប្រាក់លើកទឹកចិត្ត វីដេអូ និងសារអប់រំតាមទូរស័ព្ទ)
    - តើអ្នកដឹងទេ ការក្លាយជាសមាជិកនៃកម្មវិធីជំងឺរបេងរបស់ពួកយើង អ្នកនឹងទទួលបានការគាំទ្រពីពួកយើងបន្ថែមទៀតដូចខាងក្រោម៖
      - គាំទ្រមធ្យោបាយធ្វើដំណើរចំនួន ២០០០០រៀល
      - ថ្នាំព្យាបាលជំងឺរបេង (ប្រចាំសប្តាហ៍/ប្រចាំខែ)
      - កញ្ចប់សម្ភារៈថែទាំអ្នកជំងឺរបេង (កូនសៀវភៅតាមដានការលេបថ្នាំ ស្ទីកគ័ររំលឹកការលេបថ្នាំ កែវ និង វីតាមីនសុី)
      - វីដេអូដើម្បីរំលឹកអ្នកក្នុងការលេបថ្នាំ
      - សារអប់រំតាមទូរស័ព្ទចំនួន ៣៦សារ នឹងផ្ញើជូនទៅកាន់ទូរស័ព្ទរបស់អ្នក ចាប់ពីថ្ងៃនេះទៅរហូតដល់បញ្ចប់រយៈពេល ៦ ខែ
      - ពន្យល់ពីរបៀបប្រើប្រាស់សម្ភារៈនីមួយៗ ម្តងមួយៗ
        - បង្ហាញកញ្ចប់សម្ភារអ្នកជំងឺរបេង
        - បង្ហាញវីដេអូទី១៖ ការបង្កើតទំលាប់ក្នុងការលេបថ្នាំ
        - បង្ហាញវីដេអីទី២៖វិធីក្នុងការដោះស្រាយចំពោះផលប៉ះពាល់នៃថ្នាំ
        - បង្ហាញវីដេអីទី៣៖វិធីក្នុងការលើកទឹកចិត្តអ្នកជំងឺរបេង (បង្ហាញវីដេអូនេះ ទៅកាន់ក្រុមគ្រួសារបើពួកគាត់មកជាមួយអ្នកជំងឺ)
        - ពន្យល់អំពីកម្មវិធី សារអប់រំតាមទូរស័ព្ទ ៖ ចាក់សារទី១ ឲ្យពួកគាត់ស្តាប់
    - គ្រូពេទ្យ (TB supporter ) បោះត្រានៅលើបណ្ណបញ្ជូន បញ្ជាក់ថា “លទ្ធផលមានជំងឺរបេង”
      - ប្រសិនបើអ្នកជំងឺមានកាន់បណ្ណបញ្ជូន មកជាមួយពួកគាត់ គ្រូពេទ្យត្រូវបោះត្រានៅលើបណ្ណនោះ។
      - ប្រសិនបើអ្នកជំងឺបាត់បណ្ណបញ្ជូនរបស់ពួកគាត់ គ្រូពេទ្យត្រូវផ្តល់បណ្ណបញ្ជូនថ្មីជូនគាត់ ហើយបោះត្រាពីរកន្លែង “បានស្រាវជ្រាវរករបេង” និង “លទ្ធផលមានជំងឺរបេង”។
    - ចែករំលែកវីដេអូទៅឱ្យអ្នកជំងឺ ប្រសិនបើពួកគេមានទូរស័ព្ទ តាមរយៈតេលេក្រាម ប្លូធូ ឬហ្វេសបុក (វីដេអូទាំង៣)
  - ភ្នាក់ងារអប់រំ ចែកជូនប្រាក់លើកទឹកចិត្តទៅអ្នកជំងឺ (សរុប ៤០០០រៀល និង ២០០០០រៀល)
    - រំលឹកអ្នកជំងឺឱ្យទទួលទូរស័ព្ទ និងស្តាប់សារអប់រំ តាមការហៅទូរស័ព្ទ នៅពេលខាងមុខ។
    - ប្រាប់អ្នកជំងឺអំពី ថ្ងៃដែលត្រូវមកមណ្ឌលុសខភាពម្តងទៀត។